# លក្ខណៈ រូបរាង និងសារសំខាន់ក្នុងវិស័យវប្បធម៌នៃកុណ្ឌី នៅស្ថានីយបុរាណជើងឯក

Characteristics, Form, and Cultural Significance of the Kendi Found at the Cheung Ek Archaeological Site

*ដោយ* : **បណ្ឌិត ផុន កសិកា**

*ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ចំណេះដឹងអំពីកុលាភាជន៍អាចជួយបង្ហាញពីការយល់ដឹងអំពីសេដ្ឋកិច្ច និងរចនាសម្ព័ន្ធសង្គម ការបែងចែកកម្លាំងពលកម្ម និងការរៀបចំបរិស្ថាន អេកូសាស្ត្ររបស់សង្គម។ ទោះបីការសិក្សាកុលាលភាជន៍ខ្មែរមិនបានធ្វើឱ្យធំទូលលំទូលាយ និងស៊ីជម្រៅដូចការសិក្សាសំណង់ ប្រាសាទធំៗ ការងារស្រាវជ្រាវលើវិជ្ជានេះបាន ចាប់ផ្តើមតាំងពីដើមសតវត្សរ៍ទី១៩មកម្លេះ។ កុលាលភាជន៍ផុយយកពីស្ថានីយបុរេប្រវត្តិសាស្ត្រ ដូចជាស្ថានីយសំរោងសែន ស្ថានីយម្លូព្រៃ ស្ថានីយល្អាងស្ពាន និងស្ថានីយភូមិមូល បានកំណត់ដើម្បីធ្វើការសិក្សាស្រាវជ្រាវ។ រហូតដល់បច្ចុប្បន្ន ចំណេះដឹងកុលាលភាជន៍ផុយសម័យកាលបុរេប្រវត្តិសាស្ត្រទទួលបានពីកំណាយរបស់លោក* Louis´ Malleret *នៅស្ថានីយអូកែវក្នុងប្រទេសវៀតណាមមុនសម័យសង្គ្រាមលោកលើកទី២* (Stark 2003)។ *កំណាយរបស់លោក* Bernard Philippe Grosslier *នៅស្ថានីយសម្បូណ៌ព្រៃគុក ផ្តល់ព័ត៌មានបន្ថែមលើកុលាលភាជន៍ផុយសម័យប្រវត្តិសាស្ត្រ។ ការសិក្សាស្រាវជ្រាវបន្តបន្ទាប់មកទៀតនៅស្ថានីយអង្គរបូរីដោយក្រុមគម្រោងបុរាណវិទ្យាដីសណ្តទន្លេមេគង្គ* (Lower Mekong Archaeological Project) *នៅឆ្នាំ ១៩៩៦ បានបង្កើតសមុច្ច័យដំបូងស្តីអំពីកុលាលភាជន៍ដែលមានស្រទាប់ដីច្បាស់លាស់ ដែលតាមរយៈព័ត៌មាននេះយើងអាចកសាងឡើងវិញកាលប្រវត្តិនៃប្រភេទកុលាលភាជន៍សម្រាប់ក្នុងតំបន់* (Stark *et al. 1999*)*។ នៅពេលស្របគ្នានេះដែរ មានសេរ៉ាមិចជាច្រើនដែលបានសិក្សាដែលមានសេរ៉ាមិចមានសារធាតុរលោងរកឃើញនៅក្នុងតំបន់អង្គរ* (Grosslier 1981, Darith 2000, Rooney 2000, Franiatte 2000, Aoyagi 2000)។

កុលាលភាជន៍ផុយខ្មែរសម័យទំនើប គឺជាមុខវិជ្ជាមួយសម្រាប់អ្នកសិក្សាស្រាវជ្រាវ ស្វែង យល់ពីការវិវត្តន៍នៃផលិតកម្មកុលាល ភាជន៍ខ្មែរក្នុងប្រទេសកម្ពុជា (Cort 2000; and Muan 2000)។

## ១. ប្រវត្តិនៃការសិក្សាពីកុលាលភាជន៍នៅស្ថានីយជើងឯក

ស្ថានីយជើងឯកចាប់ផ្តើមសិក្សាស្រាវជ្រាវ ទោះបីស្ថិតក្នុងទម្រង់តូចយ៉ាងណាក្តី យើងបានទទួលលទ្ធផលជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០០០ រហូតដល់បច្ចុប្បន្ន។ ការសិក្សាពីកុលាលភាជន៍នៅ ស្ថានីយជើងឯកអាចធ្វើទៅបានដោយសារមានទិន្នន័យ ក៏ដូចជាបុរាណវត្ថុនៅមានលើស្ថានីយនោះ។ សំណល់រកឃើញមានច្រើនដូចជា គ្រឿងសំណង់ប្រាសាទបុរាណ ជាពិសេសរកឃើញនៅក្នុងបរិវេណវត្តជើងឯក។ ក្រៅពីសម្ភារៈវប្បធម៌ខាងលើ ស្ថានីយជើងឯកមានបំណែកកុលាលភាជន៍ នៅរាយប៉ាយលើស្រែទាប់ផ្ទៃលើជាច្រើន។ ការសិក្សាស្រាវជ្រាវធ្វើទោកន្ទងមក បានរកឃើញកុលាលភាជន៍ ព្រមទាំងឡជាមួយផង។

### ក-ការសិក្សាពីកុលាលភាជន៍នៅស្ថានីយជើងឯកមុនឆ្នាំ២០០៧

ស្ថានីយបុរាណជើងឯករកឃើញថ្មីៗនេះ នៅក្នុងឆ្នាំ២០០០ នៅពេលដែលលោក ផុន កសិកា សិក្សាស្រាវជ្រាវសម្រាប់សរសេរនិក្ខេបទបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់នៅរាជបណ្ឌិត្យសភាកម្ពុជា។ ការសិក្សានោះក៏បានប្រមូលកុលាលភាជន៍សម្រាប់វិភាគ។ គួរកត់សម្គាល់ដែរ ភាជន៍ភាគច្រើនជាប្រភេទភាជន៍រឹងមានសារជាតុរលោង និងគ្មានសារជាតុរលោង ព្រមទាំងកុលាលភាជន៍ផុយជាមួយគ្នាដែរ ក៏ប៉ុន្តែកុលាលភាជន៍ផុយមានចំនួនតិចតួចបើប្រៀបធៀបជាមួយកុលាលភាជន៍រឹង។ កុលាលភាជន៍ដែលយើងប្រមូលបាន គឺបានមកពីស្រែទាប់លើ។ បំណែកកុលាលភាជន៍ភាគច្រើន រើសនៅទីកន្លែងក្បែរឡដុតកុលាលភាជន៍ (ផុន កសិកា ២០០២)។ កុលាលភាជន៍ដែលរើសមកនោះ មានទាំងបំណែកតូច និងធំ ប៉ុន្តែមិនមានរូបរាងនៅល្អទាំងមូលទេ ទោះបីប្រហែលមានក្នុងដៃប្រជាជនរក្សាទុក។ បំណែកកុលាលភាជន៍ គឺជាបំណែកមាត់ បាតក្អេង ដំពួយ និងតួ។

តាមរយៈការអង្កេត យើងអាចចាត់ថ្នាក់បំណែកទាំងនោះជាពីរប្រភេទធំៗ គឺប្រភេទកុលាលភាជន៍ផុយដែលដុតក្នុងកំដៅទាប និងប្រភេទកុលាលភាជន៍រឹងដុតក្នុងកំដៅខ្ពស់។ ប្រភេទកុលាលភាជន៍រឹងជួនកាលមានលាបសារជាតុរលោងនៅផ្នែកខាងក្រៅ។ ក្រៅពីនោះ យើងសង្កេតឃើញពីបច្ចេកទេសផលិតខ្លះៗ ដូចជាការប្រើកង់ឈ្នាន់បង្វិល ឬអន្ទោក ដើម្បី

សូនឱ្យចេញជារូបរាងភាជន៍ឡើង។ យើងអាចសន្និដ្ឋានបែបនេះដោយសារ នៅផ្ទៃភាជន៍រមែងមានស្នាមខ្សែតូចៗរាងជារង្វង់។ តាមរយៈរូបរាង និងបច្ចេកទេស កុលាលភាជន៍ដែលរកឃើញទាំងនោះប្រហែលផលិតនៅសម័យក្រោយអង្គរ ហើយប្រភេទនេះសោត ក៏មានរកឃើញនៅស្ថានីយក្បែរជើងឯកដែរ ដូចជាស្ថានីយស្រែអំពិលស្ថិតក្នុងឃុំឈើទាល ស្រុកគៀនស្វាយ ខេត្តកណ្ដាល នៅស្ថានីយម្កាក់ ស្ថិតក្នុងឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល និងស្ថានីយកំផុង ស្ថិតក្នុងស្រុកមុខកំពូល ខេត្តកណ្ដាល។ នេះគឺជាការសន្និដ្ឋានតាមរយៈរូបរាង ថ្នាំរលោង និងក្បាច់ដែលមានលើភាជន៍ ក៏ប៉ុន្តែការសិក្សាវិភាគកាលបរិច្ឆេទវិទ្យុសកម្មធ្យូង ចាំបាច់ត្រូវតែធ្វើដើម្បីបញ្ជាក់អំពីអាយុកាលនៃការផលិតកុលាលភាជន៍រឹងស្ថានីយជើងឯក។

កុលាលភាជន៍ដែលរកឃើញនៅស្ថានីយជើងឯកកន្លងមកនេះភាគច្រើនជាប្រភេទខូចគុណភាពដែលគេបោះចោល ដោយសារខូចគុណភាពនៅពេលដុតរួច ឬដោយសារបែកនៅពេលយកចេញពីឡ ឬដោយសារដុតកម្ដៅមិនគ្រប់ ឬដុតលើសកំដៅក៏មាន។ ដូច្នេះហើយស្មូនតែងតែបោះវត្ថុខូចគុណភាពនោះ ចោលនៅក្បែរឡនោះតែម្ដង។

លក្ខណៈរបស់កុលាលភាជន៍នៅស្ថានីយជើងឯក គឺមានគ្រាប់ថ្មបាយក្រៀមក្នុងសាច់ភាជន៍ និងមានខ្យល់ ឬរន្ធប៉ោងក្នុងសាច់ភាជន៍។ ជាធម្មតា បើផលិតផលដុតហើយអាចយកទៅប្រើបាន គឺមិនមានខ្យល់ក្នុងសាច់ភាជន៍ទេ។ លក្ខណៈនេះអាចបង្ហាញថា ស្មូនបន្ថែមគុណភាព ទៅលើសាច់ភាជន៍ ឬជាលក្ខណៈធម្មជាតិកើតឡើងដោយសារដីឥដ្ឋមានសារធាតុផ្សេងៗក្នុងនោះ។ នេះប្រហែលមកពីការធ្វេសប្រហែសរបស់ស្មូន មិនបានយកចិត្តទុកដាក់ យកកំទេចកំទីចេញឱ្យអស់ពីដីឥដ្ឋ ឬមិនបានដំដីឥដ្ឋឱ្យហាប់ណែនល្អ មុននឹងយកទៅសូនឱ្យចេញជារូបរាងភាជន៍។

បច្ចេកទេសធ្វើសារធាតុរលោងគឺជាភស្តុតាងមួយបង្ហាញពីសំណល់រលោងនៅលើភាជន៍ ដែលរកឃើញ។ ការសិក្សាលម្អិតអំពីបច្ចេកទេសធ្វើសារធាតុរលោងមិនទាន់បានសិក្សានៅឡើយទេ។ ដូចបានលើកឡើងខាងលើ គេប្រើបច្ចេកទេសដុតកុលាលភាជន៍រឹងដោយដុតក្នុងកំដៅខ្ពស់ និងបច្ចេកទេសដុតកុលាលភាជន៍ផុយក្នុងកំដៅទាប។

ការវិភាគផ្សេងៗទៀតអាចធ្វើទៅបាន និងផ្ដល់ព័ត៌មានយល់ដឹងអំពីការផលិតកុលាលភាជន៍នៅស្ថានីយជើងឯក។ យើងសន្និដ្ឋានជាបណ្ដោះអាសន្នថា ផលិតកម្មកុលាលភាជន៍ នៅតំបន់ជើងឯកប្រហែលជាឧស្សាហកម្មផលិតកុលាលភាជន៍ដ៏សំខាន់មួយ

និងជាកន្លែងដោះដូរបច្ចេកទេសនៅក្នុងសម័យ អង្គរ និងក្រោយអង្គរ។



បំណែកបាតភាជន៍មានរន្ធខ្យល់









គម្របភាជន៍រឹងមានថ្នាំរលោងពណ៌ត្នោត



គម្របភាជន៍រឹងមានថ្នាំរលោងពណ៌ត្នោត



បាតភាជន៍រឹងមានថ្នាំរលោងពណ៌ត្នោត



បំណែកបាតជើងជាភាជន៍រឹងដុតក្នុងកម្តៅទាប

## ខ-ការសិក្សាពីកុលាលភាជន៍ កំណាយឆ្នាំ២០០៧

នៅខែកុម្ភៈ-មីនា ឆ្នាំ២០០៧ យើងបានធ្វើកំណាយស្រាវជ្រាវមួយនៅស្ថានីយបន្ទាយមូលជើងឯក (ផុន កសិកា ២០០៧)។

គោលបំណងនៃការធ្វើកំណាយគឺចង់សិក្សាស្រាវជ្រាវភូមិមូលនៅជើងឯកៈ

- ដើម្បីកត់ត្រាតាមបែបវិទ្យាទូវពល់ព័ត៌មាន ទាក់ទងនឹងភូមិមូល តាមរយៈការវិធីសាស្ត្រសិក្សាថ្មីៗ និងបច្ចេកវិទ្យាភូមិសាស្ត្រ។

- ដើម្បីផលិតឯកសារ តាមរយៈការធ្វើកំណាយ ធ្វើផែនទី ការប្រមូលសមុច្ច័យនៅស្រទាប់លើការវិភាគជាដើម ទាក់ទងនឹងសំណួរជាគន្លឹះអំពីការតាំងទីលំនៅ និងការវិវត្តទីលំនៅដ្ឋាន។

ក្នុងរយៈពេលមួយសប្តាហ៍ដំបូងនៃការធ្វើកំណាយ ឡដុតកុលាលភាជន៍មួយបានរកឃើញនៅជ្រុងខាងជើងឈាងខាងកើតនៃភូមិមូល ហើយឡមួយនេះត្រូវបំផ្លាញដោយសារម្ចាស់ដីជីកប្រឡាយ ដោយយកប្រឡាយនោះធ្វើជាព្រំដីរបស់ខ្លួន។ ការជីកប្រឡាយនេះបានបំផ្លាញរចនាសម្ព័ន្ធឡមួយភាគធំ។ យើងឃើញមានបំណែកកុលាលភាជន៍នៅរាយប៉ាយយ៉ាងច្រើនក្បែរឡ។ កុលាលភាជន៍ដែលឃើញនៅលើដីទាំងនោះជាប្រភេទកុលាលភាជន៍ផុយមានលក្ខណៈសម្គាល់ស្រដៀងនឹងកុលាលភាជន៍មកពីអង្គរបូរី (ផុន កសិកា ២០០៤)។ ក្នុងចំណោមបំណែកកុលាលភាជន៍ទាំងអស់ បំណែកដែលគួរឱ្យចាប់អារម្មណ៍ជាងគេគឺជំពួយនៃកុណ្ឌី។ ដោយសារវត្តមានកុលាលភាជន៍ទាំងនោះ យើងសម្រេចចិត្តធ្វើកំណាយដើម្បីសិក្សាពីរចនាសម្ព័ន្ធឡដែលបំផ្លាញនេះ។

ការសិក្សាវិភាគកុលាលភាជន៍ដែលយកពីស្ថានីយធ្វើឡើង ដោយវិភាគទាំងកុលាលភាជន៍ដែលយកពីរណ្តៅកំណាយឡ និងរណ្តៅកំណាយនៅទីតាំងផ្សេងៗ ព្រមទាំងកុលាលភាជន៍រើសពីស្រទាប់លើនៃស្ថានីយបន្ទាយមូលជើងឯក។

ក្រោយពីការធ្វើវិភាគ លោក ទេព សុខា បានជួសជុលនិងតំឡើងភាជន៍ឡើងវិញ។ កុលាលភាជន៍ ចំនួន៩បានរៀបឱ្យមានទ្រង់ទ្រាយពេញឡើងវិញ។

ក្រៅពីការធ្វើវិភាគ យើងបានបញ្ជូនគំរូត្បូងសម្រាប់ធ្វើវិភាគកាលបរិច្ឆេទវិទ្យុសកម្មធ្យូង។ យើងបានបញ្ជូនធ្យូង២ដុំទៅប្រទេសនូវែលហេ្សឡង់ និងវិភាគកាលបរិច្ឆេទដោយអ្នកស្រីបណ្ឌិត Dr. Nancy Beavan។

កុលាលភាជន៍គឺជាវត្ថុវប្បធម៌មួយដែលរមែងមានច្រើនជាងគេក្នុងស្ថានីយបុរាណវត្ថុវិទ្យានីមួយៗ។ កុលាលភាជន៍នៅជើងឯក រកឃើញច្រើនជាងគេ គឺប្រភេទកុលាលភាជន៍រើសពីស្រទាប់លើ ទោះបីយើង

ធ្វើកំណាយ និងប្រមូលកុលាលភាជន៍ពីរណ្ដៅកំណាយក៏ដោយ។ ប៉ុន្តែ កុលាលភាជន៍ភាគច្រើនជាបំណែក មិនមានរូបរាងពេញលេញ។

មានតែកុលាលភាជន៍ប្រភេទផុយរកឃើញនៅភូមិមូលដើងឯក លើកលែងតែកុលាលភាជន៍ ដែលរើសនៅស្រទាប់អាចជាប្រភេទកុលាលភាជន៍រឹង។

## ២. កុណ្ឌីនៅស្ថានីយជើងឯក

*កុណ្ឌី* គឺជាក្អម ឬផ្ទាំងសម្រាប់ដាក់ទឹក ធ្វើនៅតំបន់អាស៊ីអាគ្នេយ៍ នៅកំឡុងចុងសតវត្សរ៍ទី១ និងដើមសតវត្សរ៍ទី២ (Barbara Ann Kipfer: 2007 163)។ កុណ្ឌីជាប្រភេទមួយល្បីល្បាញនៅតំបន់អាស៊ីអាគ្នេយ៍។ កុណ្ឌីមានតួនាទីសំខាន់ខ្លាំងសម្រាប់ប្រើប្រាស់ក្នុងវិស័យសាសនា ក៏ដូចជាក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សនៅសម័យបុរាណ។ កុណ្ឌីអាចធ្វើពីសម្ភារៈមានតម្លៃដូចជា មាស ប្រាក់ ឬទង់ដែងមាន បង្ហាញនៅតាមបដិមា និងគំនូ ដែលគេប្រើជាកេតនភណ្ឌរបស់ព្រះព្រហ្ម ព្រះឥសូរ ឬព្រះសេអារ្យមេត្រីយ និងលោកឥសូរ កាន់ជាប់ក្នុងដៃ។ គេប្រើកុណ្ឌីជាវត្ថុដាក់ទឹកពិសិដ្ឋក្នុងពិធីសាសនាក្នុងពិធីឡើងគ្រងរាជរបស់ព្រះមហាក្សត្រ តម្រូវឱ្យព្រះមហាក្សត្រលាងសំអាតខ្លួននិងទឹកពិសិដ្ឋដែលជានិមិត្តរូបនៃសិទ្ធិកម្ម ហើយទឹកនោះ គេយកពីទន្លេពិសិដ្ឋនានា ហើយព្រះគឺជាអ្នកដែលធ្វើប្រសិទ្ធិឱ្យទឹកនោះក្លាយជាទឹកពិសិដ្ឋ (http://rooneyarchive.net/articles/kendi/kendi_album/kendi.htm)។ កុណ្ឌី ក៏សំដៅលើថូមានជំពួយ។ លោក Heidi Tan បានពិភាក្សាថា កុណ្ឌីប្រហែលធ្វើឡើងសម្រាប់ដាក់ និងចាក់ទឹក ក្នុងពិធីសាសនា។ រូបរាងមានមាត់ និងជំពួយ ប៉ុន្តែគ្មានដៃកាន់ គឺជាថូចាក់ទឹកក្នុងពិធីបុណ្យផ្សេងៗ ដែលភាសាសំស្ក្រឹតហៅថា កុណ្ឌីកា ឬកុណ្ឌី។ គេគិតថា កុណ្ឌីបានបែកសាយក្នុងតំបន់ដីសណ្ដទន្លេមេគង្គនៅកំឡុងពេលសហវត្សទី១នៃគ្រិស្តសករាជ ឬអាចមុននោះទៀត (Heidi 2003: 111)។ កុណ្ឌីមិនមានលាបថ្នាំរលោងបានផលិតយ៉ាងច្រើននៅតំបន់អាស៊ីអាគ្នេយ៍សម័យដំបូងៗ ដូចជាប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី ភូមាហ្វីលីពិន ថៃ និងវៀតណាម ក៏ប៉ុន្តែនៅមិនទាន់មានការសិក្សាស្រាវជ្រាវច្បាស់លាស់ទីតាំងធ្វើនៅឡើយដើម្បីសិក្សាពីផលិតកម្មកុណ្ឌី (http://rooneyarchive.net/articles/kendi/kendi_album/kendi.htm)។ ការសិក្សាពីរូបរាងកុលាលភាជន៍នៅស្ថានីយទ្វារវតីបង្ហាញថា ឥណ្ឌានាំចូលកុណ្ឌីច្រើនប្រភេទ។ ប្រភេទកុណ្ឌីមួយដែលមានចំនួនច្រើនជាងគេគឺពពួកមានជំពួយ។ ថូមានជំពួយ (កុណ្ឌី) យកពីកំណាយនៅស្ថានីយទ្វារវតីមានពីរប្រភេទ (Indrawooth

1985:49)។ មានរបាយការណ៍បុរាណវត្ថុវិទ្យាជាច្រើននៅតាមស្ថានីយផ្សេងៗក្នុងអាស៊ីអាគ្នេយ៍រៀបរាប់ពីកុណ្ឌី ឧទាហរណ៍ដូចជា ស្ថានីយ Beikthano ស្ថានីយអូរកែវ ស្ថានីយសម្បូណ៌ព្រៃគុកក្នុងប្រទេសកម្ពុជា និងស្ថានីយបុរាណនៅប្រទេសជ្រោយឧបទ្វីបម៉ាឡេ និងនៅប្រទេសឥណ្ឌូនេស៊ី (Indrawooth 1985: 50)។ កន្លងមក មានអ្នកស្រាវជ្រាវបារាំង ខ្មែរខ្លះបានប្រមូលកុណ្ឌីមកពីស្ថានីយជាច្រើនក្នុងប្រទេសកម្ពុជា។ កុណ្ឌីមកពីក្រុងអង្គរបូរីជាកុណ្ឌីធ្វើពីកុលាលភាជន៍ផុយដីម៉ដ្ឋល្អ។ ប្រភេទកុលាលភាជន៍ផុយដីម៉ដ្ឋល្អរកឃើញច្រើនអង្គរបូរី និងស្ថានីយក្បែរៗនោះ ហើយកុលាលភាជន៍ប្រភេទនេះស្ថិតក្នុងរណ្តៅកំណាយ ក្នុងស្រទាប់ AB-3 ដែលត្រូវគ្នានឹងអាយុកាលវិភាគវិទ្យុសកម្មធ្យូង នាសតវត្សរ៍ទី៥ដល់ទី៨(Stark 2003: 219)។



ឧទាហរណ៍នៃថូជាកុលាលភាជន៍ផុយដីម៉ដ្ឋ (កុណ្ឌី)យកពីអង្គរបូរី

ប្រភព៖ Miriam Stark, “**Angkor Borei and the Archaeology of Cambodia’s Delta Mekong**” in *Art and Archaeology of Funan Pre-Khmer Kingdom of the Lower Mekong*, Orchid Press Bangkok 2003, page. 94

ស្ថានីយភូមិស្នាយគឺជាស្ថានីយយុគដែក មានទីតាំងនៅភាគខាងជើងប្រទេសកម្ពុជា ក្នុងខេត្តបន្ទាយមានជ័យ។ លោក Yashinori Yasuda បានបើករណ្តៅកំណាយយ៉ាងធំក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ហើយលោករកឃើញកុណ្ឌីចំនួន៥ពីរណ្តៅកំណាយ (Yasuda 2008)។



កុណ្ឌីយកពីស្ថានីយភូមិស្នាយ (Courtesy of Ypshinori and Chuch Phoeun)

មានកុណ្ឌីមួយចំនួនកំពុងដាក់តាំងនៅវត្តបូរក្នុងខេត្តសៀមរាប។ កុណ្ឌីទាំងនោះភាគច្រើនជាសមុច្ច័យយកមកពីស្ថានីយភូមិស្នាយ ខេត្តបន្ទាយមានជ័យ។













កុណ្ឌីនៅវត្តបូរ ខេត្តសៀមរាប (Tep Sokha courtesy)

ក្នុងពេលធ្វើកំណាយនៅក្រុមស្រាវជ្រាវរកឃើញបំណែកកុណ្ឌី ដំពួយកុណ្ឌីនៅរណ្តៅ និងស្រទាប់ផ្ទៃលើនៃស្ថានីយ។ កុណ្ឌីស្ថានីយជើងឯកយកចេញពីរណ្តៅកំណាយក្នុងស្រទាប់ដី ដែលយើងបានយកគំរូវិភាគធ្យូង ទៅវិភាគកាលបរិច្ឆេទធ្យូង។ លទ្ធផលកាលបរិច្ឆេទបង្ហាញថា ស្រទាប់ដីនោះមានកាលបរិច្ឆេទក្នុងសតវត្សរ៍ទី ៤-៦ នៃគ្រឹស្តសករាជ។

INSTITUTE OF GEOLOGICAL AND NUCLEAR SCIENCES LTD.
PO Box 31312, Lower Hutt, New Zealand
Phone (+64 4) 570 4671, Fax (+64 4) 570 4657

RADIOCARBON CALIBRATION REPORT

NZA 29248 CONVENTIONAL RADIOCARBON AGE 1600 ± 35 years BP

Atmospheric data from Reimer et al (2004);

PJ Reimer, MGL Baillie, E Bard, A Bayliss, JW Beck, C Bertrand, PG Blackwell, CE Buck, G Burr, KB Cutler, PE Damon, RL Edwards, RG Fairbanks, M Friedrich, TP Guilderson, KA Hughen, B Kromer, FG McCormac, S Manning, C Bronk Ramsey, RW Reimer, S Remmele, JR Southon, M Stuiver, S Talamo, FW Taylor, J van der Plicht, and CE Weyhenmeyer (2004), Radiocarbon 46:1029-1058

CALIBRATED AGE in terms of confidence intervals (Smoothing parameter: 0, Offset: 0)

| | | |
|---|---|---|
| 68% confidence interval is | 419 AD to 444 AD | 1531 BP to 1506 BP (19.0% of area) |
| plus | 449 AD to 464 AD | 1501 BP to 1486 BP (9.8% of area) |
| plus | 483 AD to 533 AD | 1467 BP to 1417 BP (39.3% of area) |
| 95% confidence interval is | 394 AD to 544 AD | 1556 BP to 1406 BP (95.1% of area) |






លោក ទេព សុខា យកកុណ្ឌីចេញពីរណ្តៅកំណាយ នៅឆ្នាំ២០០៧



ទិដ្ឋភាពក្រុមស្រាវជ្រាវយកកុលាលភាជន៍ចេញពីរណ្តៅកំណាយ

INSTITUTE OF GEOLOGICAL AND NUCLEAR SCIENCES LTD.
PO Box 31312, Lower Hutt, New Zealand
Phone (+64 4) 570 4671, Fax (+64 4) 570 4657

RADIOCARBON CALIBRATION REPORT

NZA 29252 CONVENTIONAL RADIOCARBON AGE 1309 ± 35 years BP

Atmospheric data from Reimer et al (2004);

PJ Reimer, MGL Baillie, E Bard, A Bayliss, JW Beck, C Bertrand, PG Blackwell, CE Buck, G Burr, KB Cutler, PE Damon, RL Edwards, RG Fairbanks, M Friedrich, TP Guilderson, KA Hughen, B Kromer, FG McCormac, S Manning, C Bronk Ramsey, RW Reimer, S Remmele, JR Southon, M Stuiver, S Talamo, FW Taylor, J van der Plicht, and CE Weyhenmeyer (2004), Radiocarbon 46:1029-1058

CALIBRATED AGE in terms of confidence intervals (Smoothing parameter: 0, Offset: 0)

| | | |
|---|---|---|
| 68% confidence interval is | 663 AD to 709 AD | 1287 BP to 1241 BP (48.4% of area) |
| plus | 747 AD to 766 AD | 1203 BP to 1184 BP (19.1% of area) |
| 95% confidence interval is | 657 AD to 773 AD | 1293 BP to 1177 BP (95.2% of area) |




ក្រោយពីយកកុណ្ឌីពីរណ្តៅកំណាយ លោក ទេព សុខា ដែលជាអ្នកជំនាញអភិរក្សកុលាលភាជន៍យកកុណ្ឌីទៅធ្វើវិភាគនិងរៀបផ្គុំឡើងវិញ។ នៅចុងក្រោយ យើងទទួលបានកុណ្ឌី២ និងមាត់កុណ្ឌីមួយ។

-**កុណ្ឌីទី១** ៖ កុណ្ឌីនេះមានតួខ្លួនទំហំ ២៩ សង់ទីម៉ែត្រ និងកំពស់២៥ សង់ទីម៉ែត្រ។ អង្កត់ផ្ចិតរបស់មាត់ប្រវែង១២ សង់ទីម៉ែត្រ និង អង្កត់ផ្ចិតរបស់បតប្រវែង១២ សង់ទីម៉ែត្រ។ កុណ្ឌីមាន ក្អេងធំ ប៉ោង បាតមានក្បាច់ចិញ្ចៀន កវែង មាត់រីក និងមានធ្នាមធូតនៅលើមាត់។ ប្រវែងមាត់និងកស្មើគ្នា។ ផ្ទៃខាងក្នុងរលោង។ នៅលើក ក្អេង និងមាត់ មានលាបថ្នាំពណ៌ក្រហម (ទេព សុខា ២០០៨)។





កុណ្ឌីទី១ យកពីស្ថានីយដើងឯក

-**កុណ្ឌីទី២** ៖ កុណ្ឌីទី២មាន អង្កត់ ផ្ចិតតួខ្លួន២៤សង់ទីម៉ែត្រ កំពស់២៥ សង់ទីម៉ែត្រ អង្កត់ផ្ចិតមាត់៨ សង់ទីម៉ែត្រ និងអ្កត់ផ្ចិត បាត៩ សង់ទីម៉ែត្រ។ កុណ្ឌី នេះមានរាងពងក្រពើស្នាមិនសូវធំ កវែង និងបាតមានក្បាច់ចិញ្ចៀន។






កុណ្ឌីទី២ យកពីស្ថានីយដើងឯក






មាត់កុណ្ឌី យកពីស្ថានីយដើងឯក

# សន្និដ្ឋាន

គម្រោងបុរាណវិទ្យានៅដីសណ្តទន្លេមេគង្គ (Lower Mekong Archeaological Project-LOMAP) ដឹកនាំដោយលោកស្រី Miriam Stark នៅក្រុងអង្គរបូរីដែលគេសន្និដ្ឋានថាជារាជធានីរបស់ហ្វូណននៅសតវត្សរ៍ទី៥នៃគ្រិស្តសករាជ។ កុណ្ឌីយកមកពីអង្គរបូរីត្រូវគ្នានិងដំណាក់កាលវប្បធម៌ទី៣ មានកាលបរិច្ឆេទឆ្នាំ៣០០-៦០០នៃគ្រិស្តសករាជ (Bong Sovath 2003: 232) ប៉ុន្តែការសិក្សាស្រាវជ្រាវនោះមិនបនរកឃើញថាតើកុណ្ឌីនោះផលិតនៅទីណាទេ។ នេះបង្ហាញថាការសិក្សាស្រាវជ្រាវរបស់លោកស្រី Miriam Stark កន្លងមក មិនទាន់រកឃើញឡដុតកុលាលភាជន៍នៅសម័យមុនអង្គរទេ។

សម្បូរណ៍ព្រៃគុកគឺជាស្ថានីយបុរាណមួយ និងធ្លាប់ជារាជធានីរបស់ព្រះមហាក្សត្រខ្មែរ នៅសម័យមុនអង្គរ។ នៅទីនោះ មានប្រាសាទជាច្រើន និងកុលាលភាជន៍ក៏ច្រើនដែរ។ ក្នុងចំណោម កុលាលភាជន៍យកមកពីសម្បូណ៌ព្រៃគុក មានកុណ្ឌីខ្វះរកឃើញ ប៉ុន្តែមិនមានការបង្ហាញពីវត្តមាន ឡដុតកុលាលភាជន៍ណាមួយរកឃើញនៅឡើយទេ។

ស្ថានីយភូមិស្នាយ សន្មតថាជាស្ថានីយស្ថិតក្នុងយុគដែក និងបន្តរហូតដល់សម័យអង្គរ។ ដូចគ្នានឹងស្ថានីយដែលបានលើកឡើងខាងលើដែរ មិនមានការសិក្សាស្រាវជ្រាវណាមួយបញ្ជាក់ពីវត្តមានឡនៅស្ថានីយនោះ។ លោក Tan លើកឡើងថា សម្ភារៈវប្បធម៌តួយ៉ាងកុលាលភាជន៍យកពីការកំណាយ និងអាយុកាលនៅសតវត្សរ៍ទី៦ និងបន្តរដល់សម័យក្រោយៗ ដុតនៅសីតុណ្ហភាពខ្ពស់ តែផ្ទុយទៅវិញ យើងមិនបានរកឃើញកស្តុតាងឡណាមួយនៅឡើយទេ ដូច្នេះទាមទារឱ្យមានសិក្សាស្រាវជ្រាវថែមទៀត ដើម្បីធ្វើកាលបរិច្ឆេទកុលាលភាជន៍ទាំងនោះឱ្យច្បាស់លាស់ (Tan, 2003)។ ចំណែកលោក Jean Boisselier ក៏លើកឡើងថា មិនដែលរកឃើញឡនៅតាមតំបន់ដីសណ្តទន្លេមេគង្គទេ ដូច្នេះបច្ចេកទេសធ្វើឡប្រហែលមិនជាប់ទាក់ទងជាមួយការផលិតកុលាលភាជន៍ផុយក្នុងប្រទេសកម្ពុជាទេ។ លោកចង់បញ្ជាក់ថាការផលិតកុលាលភាជន៍ផុយនៅកម្ពុជាមិនមានការប្រើឡសម្រាប់ដុតនៅឡើយទេ (Boisselier, 1966)។ ចំណែកលោកស្រី Miriam Stark បញ្ជាក់ទៀតថា ពពួកកុណ្ឌីគឺជាប្រភេទនាំចូលពីបរទេស ប៉ុន្តែកុណ្ឌីយកមកពីអង្គរបូរីជាប្រភេទផលិតក្នុងស្រុក (Stark 2000: 81-82)។ លោក Bhumadhon បង្ហាញដែរថា កុណ្ឌីដំបូងៗដែលរកឃើញនៅលុពបូរី មានកាលបរិច្ឆេទក្នុងចន្លោះ ៥០០ឆ្នាំមុនគ្រិស្តសករាជ ដល់ ៥០០ឆ្នាំនៃគ្រិស្តសករាជ (Bhumadhon 1996: 7)។ លោកក៏សន្មតដែរថា មនុស្សមកពីតំបន់ខាងលិច

ប្រហែលមកពីឥណ្ឌា នាំយកកុណ្ឌីមកតំបន់លុពបូរី ហើយមនុស្សសម័យបុរាណប្រហែលប្រើវាក្នុងការប្រើប្រស់ក្នុងពិធីសាសនាផ្សេងៗ។ ការចែកចាយកុណ្ឌីធ្វើឡើងពាសពេញតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍។ ក្នុងទ្វីបអាស៊ីអ្នកបុរាណវិទូជាច្រើនជឿថា កុណ្ឌីកើតមុនគេនៅឥណ្ឌានៅមុនគ្រិស្តសករាជ ក្រោយមកបានរីកសាយភាយដល់តំបន់អាស៊ីអាគ្នេយ៍ ក្នុងពេលឥណ្ឌាពង្រីកឥទ្ធិពលរបស់ខ្លួន (Malleret 1960: 162-163, Groslier 1981: 14-15, Indrawooth 1985: 49-50, Mourer 1986: 144-147, Bhumadhon 1996: 7)។

យោងតាមកាលបរិច្ឆេទធ្យូងយកពីរណ្ដៅកំណាយនៅទីតាំងឡក្នុងស្ថានីយជើងឯក លទ្ធផលនោះបង្ហាញនៅក្នុងឆ្នាំ៣៩៤ ដល់៥៤៤នៃគ្រិស្តសករាជ (សតវត្សរ៍ទី៤-៦)។ ដូច្នេះ យើងអាចសន្និដ្ឋានថា ឡកសាងនៅក្នុងរង្វង់សតវត្សរ៍ទី៤-៦។ យ៉ាងហោចណាស់ យើងអាចដឹងច្បាស់ថា សកម្មភាពផលិតកុលាលភាជន៍នៅស្ថានីយជើងឯកអនុវត្តឡើងនៅក្នុងចន្លោះសតវត្សរ៍ទី៤-៦នៃគ្រិស្តសករាជ។ តាមរយៈកាលបរិច្ឆេទខាងលើ យើងអាចសន្មតថា កុលាលភាជន៍ផុយយកពីជើងឯកដុតក្នុងឡ។ កន្លងមកអ្នកស្រាវជ្រាវរកឃើញកុលាលភាជន៍សម័យបុរេប្រវត្តិសាស្ត្រ និងសម័យមុនអង្គរជាច្រើន ប៉ុន្តែមិនទាន់មានការសិក្សាស្រាវជ្រាវរកឃើញភស្តុតាងអំពីឡដុតកុលាលភាជន៍ផុយ ឬ ឡដុតកុណ្ឌី ក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាទេ។

ស្ថានីយជើងឯកគឺជាស្ថានីយឡមួយដែលមានអាយុកាលស្ថិតក្នុងសម័យមុនអង្គរក្នុងប្រទេសកម្ពុជា។ សម្រាប់ស្ថានីយឡក្នុងសម័យអង្គររកឃើញ និងសិក្សាស្រាវជ្រាវជាពិសេសនៅស្ថានីយឡនៅតំបន់អង្គរខេត្តសៀមរាប ប៉ុន្តែស្ថានីយឡទាំងនោះមានកាលបរិច្ឆេទស្ថិតក្នុងសម័យអង្គរ (សតវត្សរ៍ទី១០-១១-១២-១៣)។

កុណ្ឌីដែលរកឃើញនៅស្ថានីយជើងឯកមានរូបរាងប្រហែលគ្នានឹងកុណ្ឌីរកឃើញនៅស្ថានីយ ដែលរៀបរាប់ខាងលើ ទាំងស្ថានីយក្នុងប្រទេសកម្ពុជា និងស្ថានីយមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍។ យើងគួរកត់សម្គាល់ថា កុណ្ឌីរកឃើញនៅស្ថានីយដទៃមិនមានភស្តុតាងបង្ហាញពីឡដុតទេ។ កុណ្ឌីស្ថានីយជើងឯកយកចេញពីឡដែលមានអាយុកាលសតវត្សរ៍ទី៤-៦។ ដូច្នេះ ស្ថានីយជើងឯកគឺជាស្ថានីយ ផលិតកុណ្ឌីរកឃើញមុនគេបង្អស់ក្នុងតំបន់អាស៊ីអាគ្នេយ៍។ ស្ថានីយជើងឯកប្រហែលជាតំបន់ផលិត និងចែកចាយកុណ្ឌីដល់ស្ថានីយផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជានាសតវត្សរ៍ទី៤ដល់ទី៦។

# ឯកសារយោង


- Agency for Culture Affairs, Nara National Cultural Properties Research Institute, Japan, and the APSARA Authority, << Recent Research on Kilns Sites in the Agkor Area >>, in: ***Journal of Khmer Studies. Udaya***, APSARA Authority, Numer 1, April 2000, p. 217-234. - Bernard (H. Russell), ***Research Methods in Anthropology***, Second Edtion, Almitara Press, London, 1995.

- Boisselier (Jean), ***ASIA DU SUD – EAST***, Tome. I LE CAMBODGE, Paris, 1966.

- Boisselier (Jean), << Les Anciennes Capitals du Cambodge >>, in: ***Cambodge. Revue illustrée Khmère***, No. 1, January 1953.

- Boisselier (Jean), ***Le Cambodge***, Tome I, Paris Édition A. et J. Picard et $C^{ie}$ 1966.

- Bong Sovath

  2003 *The Ceramic Chronology of Angkor Borei, Takeo Province, Southern Cambodia*. Ph.D. dissertation, Department of Anthropology, University of Hawai'i at Mānoa.

- Briggs (L. Palmer), ***The Ancient Khmer Empire***, New Series-Volume. 41, Part. I, The American Philosophical Society, New York, 1951.

- Chandavij (Natthapatra), ***Chinese Ceramics from the Archaeological Site in Thailand***, Deparment of Fine Arts, Bangkok, 1994.

- Cort, Louise Aliso

  Khmer Stoneware Ceramics", in: ***Asian Tradition In Clay***, Smithsonian Institution, Washington, D.C.

- Fujiwara (Hiroshi), ***Khmer Ceramics from the Kamratan Collection. Introduction by Dawn F. Rooney***, Singapore, 1990.

- Indrawooth, Phasook

  1985 *Index Pottery of Dvāravati Period.* Department of Archaeology, Silpakorn University.

- Rooney (Dawn), ***Khmer Ceramics***, Oxford In Asia Studies In Ceramics, Singapore, Oxford University Press, 1984.

- Stark, Miriam T.

  1999 Social Dimensions of Technical Choice in Kalinga Ceramic Traditions. In *Material Meanings: Critical Approaches to Interpreting Material Culture*, edited by E. Chilton, pp. 24-43. University of Utah Press, Salt Lake City.

  2000 Pre-Angkor Earthenware Ceramics from Cambodia's Mekong Delta. *Udaya: Journal of Khmer Studies* 1:69-90.

2001 Some Preliminary Results of the 1999-2000 Archaeological Field Investigations at Angkor Borei, Takeo Province. *Udaya: Journal of Khmer Studies* 2:19-35.

2001 ***Cambodia***, in Encyclopedia of Archaeology: History and Discoveries/ edited by Tim Murray, 2001

- Tan, Heidi
  2003 Remarks on the Pottery of Oc Eo. In *Art and Archaeology of Funan*. Orchid Press, Bangkok.
- Tep, Sokha
  2008 Ceramics Conservation of Chueng Ek. Unpublished report at Ceramics Conservation Lab, Phnom Penh.
- Tharapong, Srisuchat and Amara, Srisuchat
  1989 Introducing Buriram Ceramics and Kiln, in: ***Journal of Silpakorn***, Vol. 32, No. 6.